លោកជំទាវ Bu Jianguo
ឯកអគ្គរដ្ឋទូតនៃសាធារណរដ្ឋប្រជាមានិតចិនប្រចាំព្រះរាជាណាចក្រកម្ពុជា
អគារលេខ ១៥៦ មហាវិថីម៉ៅសេទុង
រាជធានីភ្នំពេញ, រាជាណាចក្រកម្ពុជា (P.O. Box 26)

ថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០១៤

ជម្រាបមកលោកជំទាវ Bu Jianguo

**សំណើបន្ទាន់សុំលោកជំទាវពិចារណាលើការវិនិយោគរបស់ប្រទេសចិន**
**ទៅលើទំនប់វារីអគ្គិសនីសេសានក្រោម២ នៅខេត្តស្ទឹងត្រែង នៃប្រទេសកម្ពុជា**

យើងខ្ញុំជាក្រុមអង្គការសង្គមស៊ីវិលធ្វើការលើផ្នែកបរិស្ថាន និងសង្គមនៅក្នុងតំបន់ទន្លេមេគង្គ។ យើងខ្ញុំសូមយោងទៅលើ "សេចក្តីប្រកាសរួមរបស់បណ្តាសហាគមន៍នៅតាមដងទន្លេសេសាន ស្រែពក និងសេកុង (ទន្លេ៣) ដែលបានដាក់ជូនលោកជំទាវកាលពីថ្ងៃទី១២ ខែធ្នូ ឆ្នាំ២០១៣។ បណ្តាសហាគមន៍នៅតាមដងទន្លេទាំង៣ ដែលប្រឈមផលប៉ះពាល់ដោយទំនប់វារីអគ្គិសនីសេសានក្រោម២ ភាគច្រើននៃសហាគមន៍ទាំងនោះជាជនជាតិដើមភាគតិច មានក្តីបារម្ភយ៉ាងខ្លាំងចំពោះផលប៉ះពាល់ទៅលើជីវភាពរស់នៅ និងការប្រកបរបរចិញ្ចឹមជីវិត ដែលបណ្តាលមកពីគម្រោងសាងសង់ទំនប់នេះ និងបានស្វែងរកអន្តរាគមន៍ឲ្យយើងខ្ញុំជួយដល់សហាគមន៍។ សហាគមន៍យើងខ្ញុំជឿថា ត្រូវតែបញ្ឈប់គម្រោងនេះជាបន្ទាន់ ដោយសារតែគ្រោះថ្នាក់យ៉ាងខ្លាំងទៅលើបរិស្ថាន និងបណ្តាសហាគមន៍នៅតាមដងទន្លេទាំង៣ និងនៅតាមទន្លេមេគង្គ នៅក្នុងប្រទេសកម្ពុជា ក៏ដូចជានៅប្រទេសជិតខាងនានាទៀតដែរ។

យើងខ្ញុំសូមសំណូមពរ លោកជំទាវធ្វើយ៉ាងណាឲ្យប្រាកដថា បណ្តាក្រុមហ៊ុនចិនដែលកំពុងវិនិយោគលើគម្រោងនេះ រួមទាំងក្រុមហ៊ុន Hydrolancang International Energy Co. Ltd និងក្រុមហ៊ុនធំ Huaneng Group ត្រូវប្រតិបត្តិក្រមសីលធម៌ទទួលខុសត្រូវតាមផ្លូវច្បាប់របស់ខ្លួនពាក់ព័ន្ធនឹងគម្រោងសាងសង់ទំនប់សេសានក្រោម២។ លិខិតនេះ សូមលើកមកបង្ហាញអំពី

ការទទួលខុសត្រូវរបស់ក្រុមហ៊ុន Hydrolancang និងក្រុមហ៊ុន Huaneng ទៅតាមច្បាប់ជាតិ និងអន្តរជាតិមួយចំនួន។ យើងខ្ញុំកត់សម្គាល់ឃើញថា បណ្តាក្រុមហ៊ុនចិនដែលវិនិយោគទុនលើគម្រោងនេះ ត្រូវបានរដ្ឋាភិបាលចិនរកឃើញថា មិនបានគោរពច្បាប់ឲ្យបានត្រឹមត្រូវទេ ពាក់ព័ន្ធនឹងគម្រោងសាងសង់ទំនប់វារីអគ្គិសនីនៅក្នុងប្រទេសចិន និងពាក់ព័ន្ធនឹងបណ្តាគម្រោងនានាដោយបានអនុវត្តនីតិវិធីផ្លាស់ប្តូរទីលំនៅ និងគោលនយោបាយផ្តល់សំណងមិនបានត្រឹមត្រូវ។[1] យើងខ្ញុំព្រួយបារម្ភថា បណ្តាសហគ្រាសរដ្ឋនៃប្រទេសចិន អាចនឹងធ្វើរឿងដដែលនេះទៀត ដោយការប្រតិបត្តិមិនបានល្អត្រឹមត្រូវនៅប្រទេសកម្ពុជា។

រហូតមកដល់ពេលនេះ មានការវាយតម្លៃផលប៉ះពាល់បរិស្ថាននិងសង្គម ដោយសារការអនុវត្តគម្រោង តិចតួចណាស់ ហើយពុំមានការវាយតម្លៃផលប៉ះពាល់ឆ្លងប្រទេសឡើយ។ ការផ្សព្វផ្សាយ និងតម្លាភាពព័ត៌មានពាក់ព័ន្ធនឹងទំនប់វារីអគ្គិសនីសេសានក្រោម២ រហូតមកដល់ពេលនេះ មិនគ្រប់គ្រាន់ទាល់តែសោះ គឺបានផ្សព្វផ្សាយព័ត៌មាន តិចតួចបំផុត ដោយពុំបានផ្តល់ ព័ត៌មានទៅបណ្តាសហគមន៍ដែលប្រឈមផលប៉ះពាល់ដោយសារគម្រោង ព្រមទាំងពុំបានពិគ្រោះយោបល់ ឬឲ្យភាគីពាក់ពន្ធដែលប្រឈមផលប៉ះពាល់ចូលរួម ក្នុងការធ្វើសេចក្តីសម្រេចឲ្យបានត្រឹមត្រូវឡើយ។

គម្រោងទំនប់វារីអគ្គិសនីសេសានក្រោម២ មានភាពចម្រូងចម្រាស់យ៉ាងខ្លាំងទាំងនៅក្នុងតំបន់ និងអន្តរជាតិ ដោយសារតែផលប៉ះពាល់ឆ្លងប្រទេស។ យើងបារម្ភថា វាអាចគំរាមដល់ស្ថិរភាពតំបន់ និងធ្វើឲ្យបាក់មុខមាត់នៃការវិនិយោគរបស់ប្រទេសចិន។ តាមការវិភាគវិទ្យាសាស្ត្រនាពេលថ្មីៗនេះ បានប៉ាន់ស្មានថា ផលប៉ះពាល់បរិស្ថាន និងសង្គមដែលបណ្តាលមកពីគម្រោងសាងសង់ទំនប់វារីអគ្គិសនីសេសានក្រោម២ អាចនឹងក្លាយកាន់តែធំទៅៗ និងធ្ងន់ធ្ងរទៅៗ

[1] Ministry of Environmental Protection of the People's Republic of China, "MEP Suspended Approvals of EIA for Hydropower Development Projects of China Huaneng Group and China Huadian Corporation to Control Illegal Construction Projects and Energy-intensive and High-polluting Overlapping Construction Projects", 11 June 2009, available at: http://english.mep.gov.cn/News_service/news_release/200907/t20090723_156677.htm; 水电移民返贫谁之过? 发表时间: 2009-10-28 来源：中国环境报第 7 版, available at: http://www.cenews.com.cn/xwzx/sj/200910/t20091028_624016.html; Worrell, S, 'Dam firm violated law', *Phnom Penh Post*, 5 June 2013, at: www.phnompenhpost.com/national/dam-firm-violated-law.

,

ដោយធ្វើឲ្យខូចខាតយ៉ាងធ្ងន់ធ្ងរនៅក្នុងតំបន់ និងបណ្តាសហាគមន៍នានានៅក្នុងប្រទេសកម្ពុជា ក៏ដូចជានៅក្នុងប្រទេសជិតខាង ដូចជាប្រទេសឡាវ ថៃ និងប្រទេសវៀតណាម។

ក្នុងនាមលោកជំទាវជាតំណាង និងទីប្រឹក្សាមួយរូបរបស់រដ្ឋាភិបាលចិន ក្នុងទំនាក់ទំនងរបស់ខ្លួនជាមួយរដ្ឋាភិបាល កម្ពុជា យើងខ្ញុំសូមសំណូមពរលោកជំទាវធ្វើយ៉ាងណាធានាថា ភាគីពាក់ព័ន្ធនានានៅក្នុងរដ្ឋាភិបាលចិន ទទួលបានរបាយការណ៍សង្ខេបស្តីពីក្តីបារម្ភចំពោះតួនាទីរបស់ក្រុមហ៊ុន Huaneng ក្នុងការអភិវឌ្ឍទំនប់វារីអគ្គិសនីសេសានក្រោម២ និងអំពីផលវិបាកចំពោះបរិស្ថាន និងបណ្តាសហាគមន៍។ ខាងក្រោមនេះ គឺជាលទ្ធផលរកឃើញ និងអនុសាសន៍មួយចំនួនពាក់ព័ន្ធបញ្ហានេះ។

## ការវាយតម្លៃអំពីផលប៉ះពាល់មិនគ្រប់ជ្រុងជ្រោយ

ការសិក្សាវិទ្យាសាស្ត្របានព្រមានឲ្យដឹងថា ផលប៉ះពាល់ដែលបណ្តាលមកពីទំនប់វារីអគ្គិសនីសេសានក្រោម២ នឹងមានទំហំកាន់តែធំជាងអ្វីដែលបានលើកឡើងនៅក្នុងរបាយការណ៍ស្តីពីការវាយតម្លៃផលប៉ះពាល់បរិស្ថាន និងនៅក្នុងផែនការគ្រប់គ្រងបរិស្ថាន[2]។ វារីសាស្ត្រ ការផ្លាស់ទីរបស់ត្រី និងប្រព័ន្ធបរិស្ថានធម្មជាតិ នៃប្រព័ន្ធទន្លេសេសាន ស្រែពក និងទន្លេសេកុង មិនអាចផ្តាច់ទំនាក់ទំនងគ្នាទៅនឹងទន្លេមេគង្គ និងទន្លេសាបបានឡើយ។ ការសិក្សានោះបានប៉ាន់ស្មានថា ទំនប់វារីអគ្គិសនីសេសានក្រោម២ នឹងនាំឲ្យមានការបាត់បង់ជីវមាសត្រី៩,៣% ក្នុងអាងទន្លេមេគង្គទាំងមូល គឺត្រីប្រហែល២០០០០០តោនក្នុង១ឆ្នាំ[3] ដែលនេះស្មើពី២០០លានដុល្លារ ទៅ៣៦០ដុល្លារក្នុង១ឆ្នាំ ក្នុងតម្លៃលក់លើកទី១ ដែលជាចំនួនច្រើនជាងប្រាក់ចំណូលប្រចាំឆ្នាំដែលត្រូវរកបានពីទំនប់វារីអគ្គិសនីសេសានក្រោម២ច្រើនណាស់។[4] ទំនប់វារីអគ្គិសនីនេះ នឹងបណ្តាលឲ្យមានការផ្លាស់ប្តូររំហូរវារីជាតិយ៉ាងខ្លាំងក្នុងទន្លេមេគង្គ និងធ្វើឲ្យ

[2] Ziv, G.; Baran, E.; Nam, S.; Rodríguez-Iturbe, I.; & Levin-Simon A., (2012) *'Trading-off fish biodiversity, food security, and hydropower in the Mekong River Basin'* Proceedings of the National Academy of Sciences of the United States of America, 28 January 2012; Baird, I., (2009), *'Best Practices in Compensation and Resettlement for Large Dams: The case of the Lower Sesan 2 Hydropower Project in Northeastern Cambodia'*, The Rivers Coalition of Cambodia, Phnom Penh

[3] Ziv et al (2012), supra note 2.

[4] The above figures are calculated using $1 - $1.80 per kg first sale value, as utilized in the Strategic Environmental Assessment report commissioned by the Mekong River Commission: International Centre For Environmental Management (ICEM), Strategic Environmental Assessment of Hydropower on the Mekong Mainstream at 8 (2010), http://www.mrcmekong.org/assets/Publications/Consultations/SEA-Hydropower/SEA-Main-Final-Report.pdf.

កករបាតុដីថយចុះប្រហែលពី៦ទៅ៨ភាគរយ[5] ដោយធ្វើឲ្យជីវជាតិដី និងផលិតកម្មកសិកម្មថយចុះ នៅក្នុងតំបន់ទឹកជំនាន់ទន្លេមេគង្គ និងដីសណ្តាមេគង្គ។

ត្រីជាប្រភពនៃការប្រកបរបរចិញ្ចឹមជីវិតយ៉ាងសំខាន់សម្រាប់ប្រជាជនកម្ពុជា និងជាប្រភពចំណីអាហារយ៉ាងសំខាន់សម្រាប់បណ្តាសហគមន៍នៅតាមទន្លេសេសាន និងទន្លេមេគង្គ ព្រមទាំងទន្លេសាប។[6] ការថយចុះត្រីយ៉ាងគំហុកបែបនេះ នឹងធ្វើឲ្យមានបញ្ហាចំណីអាហារ និងសុខភាពយ៉ាងធ្ងន់ធ្ងរ និងធ្វើឲ្យភាពក្រីក្រកាន់តែខ្លាំង និងអារូបត្ថម្ភថយចុះ។ ការបាត់បង់ចំណីអាហារ ប្រូតេអ៊ីន អាហារបំប៉នសំខាន់ៗ ការបំផ្លាញជីវជាតិដី ដីកសិកម្ម ប្រព័ន្ធបរិស្ថានធម្មជាតិ និងជីវចម្រុះ នឹងធ្វើឲ្យប៉ះពាល់ដល់សហគមន៍ច្រើននៅទូទាំងប្រទេសកម្ពុជា វៀតណាម ដីសណ្តា និងប្រទេសនៅខាងលើខ្សែទឹក នៅតាមទន្លេមេគង្គក្នុងប្រទេសឡាវ ប្រទេសថៃ និងអាចគំរាមដល់សន្តិសុខស្បៀងអាហារនៅទូទាំងតំបន់។

ដោយសាររបាយការណ៍ស្តីពីការវាយតម្លៃផលប៉ះពាល់បរិស្ថានដែលមានស្រាប់នោះ ពិនិត្យតែលើផលប៉ះពាល់នៅតាមតំបន់នៅជុំវិញគម្រោងទំនប់វារីអគ្គិសនី មើលទៅវាហាក់ដូចជាមិនបានប្រតិបត្តិតាមលក្ខខណ្ឌនៃច្បាប់ប្រទេសកម្ពុជាទេ ហើយស្ថិតនៅក្រោមបទដ្ឋាន ដែលច្បាប់ស្តីពីបរិស្ថានរបស់ប្រទេសចិនកំណត់នោះឆ្ងាយណាស់[7] មិនបានសិក្សាអំពីផលប៉ះពាល់ដែលអាចកើតឡើងដោយសារគម្រោង ជាពិសេសបណ្តាផលប៉ះពាល់ដែលគេ "ចាត់ទុកថាមានផលប៉ះពាល់ធ្ងន់ធ្ងរដល់ធនធានធម្មជាតិ ប្រព័ន្ធបរិស្ថានធម្មជាតិ សុខភាព និងសុខុមាលភាពរបស់ប្រជាជន"។[8] យើងពុំបានដឹងអំពីការសិក្សាថ្មីស្តីពីការវាយតម្លៃផលប៉ះពាល់បរិស្ថានដែលធ្វើដោយ ក្រុមហ៊ុន Hydrolancang ដើម្បីធ្វើឲ្យប្រាកដថា មានការប្រតិបត្តិតាមលក្ខខណ្ឌតម្រូវទាំងនោះណាស់។

---

[5] Ketelson, T., International Center for Environmental Management, cited in Vrieze, P, & Chhorn C.,"The Battle for the 3S Rivers." *The Cambodia Daily,* 10 September 2011.

[6] Fish are the primary form of protein in the diet of 75% of rural Cambodians: FAO. *National Fishery Sector Overview: Cambodia.* Food and Agriculture Organization of the United Nations, Mar. 2011; p.8.

[7] *Law on Environmental Impact Assessment* (promulgated by the Standing Committee of the National People's Congress., Oct. 28, 2002, effective Sept. 1, 2003) (P.R.C.), see Articles 4, 7, 10.

[8] Royal Government of Cambodia, *Subdecree on Environmental Impact Assessment Process*,No: 72. ANRK.BK, Phnom Penh, August 11,1999, Article 8.

## ចាំបាច់ត្រូវមានការវាយតម្លៃផលប៉ះពាល់ឆ្លងប្រទេស

ក្រៅពីការប៉ាន់ស្មានផលប៉ះពាល់ឆ្លងប្រទេសដែលបណ្តាលមកពីទំនប់វារីអគ្គិសនីសេសានក្រោម២ ពុំឃើញមានសញ្ញាណាមួយដែលបង្ហាញថា មានការវាយតម្លៃផលប៉ះពាល់បរិស្ថានឆ្លងប្រទេស ឬមានការបង្ហាញព័ត៌មានស្តីពីផលប៉ះពាល់ នៅក្នុងប្រទេសជិតខាងឡើយ។ ការវាយតម្លៃបែបនេះនឹងជួយដល់ការគ្រប់គ្រងហានិភ័យបរិស្ថាននិងសង្គមប្រកបដោយតម្លាភាព។ លើសពីនេះទៅទៀត ច្បាប់ប្រពៃណីអន្តរជាតិ និងវិធីប្រតិបត្តិល្អបំផុតជាលក្ខណៈអន្តរជាតិ បានកំណត់លក្ខខណ្ឌឲ្យធ្វើការវាយតម្លៃ និងផ្សព្វផ្សាយផលប៉ះពាល់ឆ្លងប្រទេសសំខាន់ៗ។[9] តុលាការយុត្តិធម៌អន្តរជាតិ បានបញ្ជាក់ថា ត្រូវមាន "លក្ខខណ្ឌតម្រូវទៅតាមច្បាប់អន្តរជាតិទូទៅឲ្យអនុវត្តការវាយតម្លៃផលប៉ះពាល់បរិស្ថាន នៅកន្លែងណាដែលសំណើគម្រោងឧស្សាហកម្មអាចកើតមានហានិភ័យខ្ពស់ក្នុងបរិបទឆ្លងប្រទេស ជាពិសេស នៅតំបន់ដែលប្រើធនធានរួមគ្នា"។[10] មានកិច្ចព្រមព្រៀងអន្តរជាតិជាច្រើន ដែលផ្តល់ការណែនាំអំពីវិធី អនុវត្តល្អបំផុត សម្រាប់ការវាយតម្លៃផលប៉ះពាល់បរិស្ថានឆ្លងប្រទេស។ ឧទាហរណ៍ "អនុសញ្ញាអេស្ប៉ូ Espoo Convention" ដាក់លក្ខខណ្ឌលើការវាយតម្លៃផលប៉ះពាល់ឆ្លងប្រទេស មុនពេលអនុម័តគម្រោងណាមួយ និងបញ្ចូលលក្ខខណ្ឌតម្រូវឲ្យមានការចូលរួមជាសាធារណៈ ព្រមទាំងជូនដំណឹងទៅប្រជាជនដែលប្រឈមផលប៉ះពាល់ឆ្លងប្រទេស។[11]

## ការផ្សព្វផ្សាយ និងតម្លាភាពព័ត៌មាន

ក្រុមហ៊ុនរៀបចំគម្រោង ដូចជាក្រុមហ៊ុន វារីអគ្គិសនីសេសានក្រោម២ បានផ្តល់ព័ត៌មានតិចតួចណាស់ទៅបណ្តាសហគមន៍ដែលស្ថិតនៅក្នុងការដ្ឋាននៃគម្រោង ពាក់ព័ន្ធនឹងផលប៉ះពាល់បណ្តាលមកពីគម្រោង និងផែនការផ្លាស់ប្តូរទៅទីតាំងថ្មី។ លើសពីនេះទៅទៀត ក្រុមហ៊ុនទាំងនោះ មិនបានបង្ហាញព័ត៌មានណាមួយ ឬពុំបានពិគ្រោះយោបល់ ពាក់ព័ន្ធនឹងគម្រោង ជាមួយ

[9] United Nations Conference on Environment and Development: Rio Declaration on Environment and Development, 14 June 1992, 31 I.L.M. 874, Article 19.
[10] *Pulp Mills on the River Uruguay*, (Argentina v. Uruguay), Provisional Measures, Order of 13 July 2006, I.C.J. Reports 2006, p. 113ICJ (2010), para. 204.
[11] See Convention on Environmental Impact Assessment in a Transboundary Context (Espoo Convention) (25 Feb. 1991), Articles 2(2), 2(3), 2(6).

សហគមន៍នានា ផ្សេងទៀត ដែលប្រឈមផលប៉ះពាល់នៅក្នុងប្រទេសកម្ពុជា និងបណ្ដាប្រទេសជិតខាងទេ។ មែនហើយ ដោយសារតែរបាយការណ៍ស្ដីពីការវាយតម្លៃផលប៉ះពាល់បរិស្ថានមានកម្រិត ដូច្នេះការបង្ហាញ ឬផ្សព្វផ្សាយព័ត៌មានពេញលេញគ្រប់គ្រាន់អំពីផលប៉ះពាល់ដោយសារគម្រោង ឬការពិគ្រោះយោបល់ជាមួយបណ្ដាសហគមន៍ដែលប្រឈមផលប៉ះពាល់មិនអាចទៅរួចទេ។

ច្បាប់ប្រទេសកម្ពុជា[12] ក៏ដូចជាបទដ្ឋានដែលមាននៅក្នុងច្បាប់ប្រទេសចិន[13] និងវិធីប្រតិបត្តិល្អបំផុតអន្តរជាតិ[14] ដែលច្បាប់នីមួយៗមានបញ្ញូលកាតព្វកិច្ចក្នុងការរៀបចំ និងផ្សព្វផ្សាយ របាយការណ៍ស្ដីពីការវាយតម្លៃផលប៉ះពាល់ បើកសវនាការសាធារណៈ បញ្ចូលបណ្ដាសហគមន៍ និងភាគីពាក់ព័ន្ធដែលប្រឈមផលប៉ះពាល់ទៅក្នុងដំណើរការនៃការវាយតម្លៃ ព្រមទាំងផ្ដល់ឱកាសឲ្យសាធារណៈផ្ដល់យោបល់។ លើសពីនេះទៅទៀត សេចក្ដីប្រកាសស្ដីពីសិទ្ធិជនជាតិដើមភាគតិច របស់អង្គការសហប្រជាជាតិ[15] ដែលទាំងប្រទេសកម្ពុជា និងប្រទេសចិនបានអនុម័តនោះ ហាមប្រាមមិនឲ្យផ្លាស់ប្ដូរជនជាតិដើមភាគតិចចេញពីដីរបស់ពួកគាត់ ដោយគ្មានការយល់ព្រមមុន ដោយគ្មានការបង្ខិតបង្ខំ និងច្បាស់លាស់ និងមានការយល់ព្រមទទួលសំណងដោយសមរម្យនិងស្មើភាពឡើយ។[16]

យើងខ្ញុំសូមអរគុណណាស់ដែលរដ្ឋាភិបាល និងបណ្ដាក្រុមហ៊ុនចិនដែលពាក់ព័ន្ធចង់ជួយប្រទេសកម្ពុជាក្នុងការបង្កើនផលិតកម្មថាមពល ដើម្បីបំពេញតម្រូវការអភិវឌ្ឍន៍ប្រទេស។ ប៉ុន្តែ ការខកខានមិនបានឲ្យបណ្ដាសហគមន៍ និងសង្គមស៊ីវិលចូលរួម និងផ្ដល់លទ្ធភាពឲ្យពួកគាត់លើកឡើងអំពីក្ដីបារម្ភរបស់គាត់ ទំនងដូចជា ធ្វើឲ្យក្រុមហ៊ុនទាំងនោះផ្ដោតការប្រឹងប្រែងទៅលើការជំទាស់នឹងគម្រោងទៅវិញ។ ការជំទាស់បែបនោះ អាចគំរាមកំហែងដល់និរន្តរភាព

---

[12]Royal Government of Cambodia, *Environmental Protection and Natural Resource Management Law* (1996), Preah Reach Kram/NS-RKM-1296/36; *Ibid*, see Article 1.

[13]*Law on Environmental Impact Assessment* (promulgated by the Standing Committee of the National People's Congress., Oct. 28, 2002, effective Sept. 1, 2003) (P.R.C.) atArticle 5; *Provisional Measures on Public Participation in Environmental Impact Assessment* (promulgated by SEPA, Feb. 14, 2006, effective Mar. 18, 2006).

[14] See, for example, United Nations, *Rio Declaration on Environment and Development* 1992, UN Doc. A/CONF.151/26 (vol. I); 31 ILM 874 (1992), Principle 10; United Nations Economic Commission for Europe, *Convention on Access to Information, Public Participation in Decision-Making and Access to Justice in Environmental Matters* 1998 (Aarhus Convention), United Nations, *Treaty Series* , vol. 2161, p. 447.

[15] United Nations *Declaration on the Rights of Indigenous Peoples*: A/RES/61/295, adopted by the General Assembly 2 October 2007.

[16] Ibid, Article 10.

និងបង្ខូចមុខមាត់នៃការវិនិយោគរបស់ប្រទេសចិន ដោយធ្វើឲ្យប៉ះពាល់ដល់ឱកាសវិនិយោគសម្រាប់ពេលអនាគត។

## ស្វ័យទទួលខុសត្រូវរបស់ក្រុមហ៊ុនចិន

រដ្ឋាភិបាលចិនបានចេញ *គោលការណ៍ណែនាំសម្រាប់ការពារបរិស្ថានក្នុងការវិនិយោគ និងក្រុមហ៊ុនបរទេស* (គោលការណ៍ណែនាំស្តីពីបរិស្ថាន)[17] ដែលអនុវត្តចំពោះ SOEs។ គោលការណ៍ណែនាំនេះបញ្ជាក់ថា ដំណើរការធ្វើផែនការ និងពិគ្រោះយោបល់សម្រាប់គម្រោងវិនិយោគត្រូវលើកកម្ពស់ការអភិវឌ្ឍសេដ្ឋកិច្ចមូលដ្ឋានប្រកបដោយភាពសុខដុមរមនា លើកកម្ពស់បរិស្ថាន និងសហគមន៍ ព្រមទាំងត្រូវគោរព ជំនឿសាសនា និងប្រពៃណីវប្បធម៌របស់ម្ចាស់ស្រុក។ គោលការណ៍ណែនាំនេះ តម្រូវឲ្យក្រុមហ៊ុនអភិវឌ្ឍន៍គម្រោងពិចារណាលើផលប៉ះពាល់សង្គម ដែលបណ្តាលមកពីគម្រោង និងត្រូវព្យាយាមការពារមរតកវប្បធម៌ និងកាត់បន្ថយផលប៉ះពាល់ធ្ងន់ធ្ងរផ្សេងៗទៀត។[18] ការគំរាមកំហែងយ៉ាងធ្ងន់ធ្ងរ ដែលបណ្តាលមកពីទំនប់វារីអគ្គិសនីសេសានក្រោម២ ទៅលើមុខរបរ ប្រពៃណី និងសុខុមាលភាពរបស់ប្រជាជន ព្រមទាំងចំណុចខ្វះខាតក្នុងការពិគ្រោះយោបល់ជាមួយបណ្តាសហគមន៍ដែលប្រឈមផលប៉ះពាល់ បញ្ជាក់ថា គម្រោងនេះមិនប្រតិបត្តិតាមគោលការណ៍ណែនាំស្តីពីបរិស្ថានទេ និងមិនទ្រទ្រង់ដល់ការអភិវឌ្ឍប្រកបដោយនិរន្តរភាព តាមបំណងក្នុងការលើកកម្ពស់របស់គោលការណ៍ណែនាំនេះទេ។[19]

*គោលការណ៍ណែនាំរបស់អង្គការសហប្រជាជាតិស្តីពីធុរកិច្ចនិងសិទ្ធិមនុស្ស*[20] (គោលការណ៍ណែនាំ) បានអនុម័តដោយក្រុមប្រឹក្សាសិទ្ធិមនុស្សនៃអង្គការសហប្រជាជាតិ ដែលនៅក្នុងក្រុមប្រឹក្សានោះមានប្រទេសចិនជាសមាជិកដែរ។ យោងតាមគោលការណែនាំនេះ បណ្តាក្រុមហ៊ុនចិនមានកាតព្វកិច្ចត្រូវគោរពសិទ្ធិមនុស្ស និងត្រូវការពារ ព្រមទាំងកាត់បន្ថយផលប៉ះពាល់សិទ្ធិ

---

[17] *Guidelines for Environmental Protection in Foreign Investment and Cooperation*, issued by Ministry of Commerce of the People's Republic of China and Ministry of Environmental Protection of the People's Republic of China, Shang He Han [2013] No. 74, Date of Issuance: February 18, 2013.

[18] Articles 3, 9.

[19] Articles 4, 21.

[20] Office of the High Commissioner on Human Rights, *UN Guiding Principles on Business and Human Rights: Implementing the Protect, Respect, Remedy Framework* (2011), available at: www.ohchr.org/Documents/Publications/GuidingPrinciplesBusinessHR_EN.pdf.

មនុស្សធ្ងន់ធ្ងរទាំងអស់ ដែលពាក់ព័ន្ធនឹងដំណើរការអនុវត្តគម្រោង រួមទាំងការពារសន្តិសុខ ស្បៀង សុខុមាលភាព និងរបរចិញ្ចឹមជីវិត។[21] ក្រុមហ៊ុនចិនត្រូវទទួលខុសត្រូវធានាថា SOEs ដូចជាក្រុមហ៊ុន Huaneng និងក្រុមហ៊ុន Hydrolancang ប្រតិបត្តិតាមគោលការណ៍ណែនាំនេះ និងត្រូវចាត់វិធានការបង្ការសិទ្ធិមនុស្សឲ្យបានម៉ត់ចត់។[22]

*សំណូមពរចំពោះរដ្ឋាភិបាលចិន*

ទំនប់វារីអគ្គិសនីសេសានក្រោម២ មានផលប៉ះពាល់បរិស្ថាននិងសង្គម ព្រមទាំងអាចរារាំងដល់កិច្ចប្រឹងប្រែងរបស់រដ្ឋាភិបាលចិន ក្នុងការរួមចំណែកធ្វើឲ្យមានកំណើនសេដ្ឋកិច្ច កិច្ចការពារបរិស្ថាន និងការអភិវឌ្ឍដោយនិរន្តរភាពតាមរយៈគម្រោងវិនិយោគរបស់ខ្លួន។ យើងសូមអំពាវនាវទៅរដ្ឋាភិបាលចិនដូចខាងក្រោម៖

- ធ្វើអន្តរាគមន៍ទៅក្រុមហ៊ុន Huaneng និងក្រុមហ៊ុន Hydrolancang ដើម្បីឲ្យក្រុមហ៊ុននេះបញ្ឈប់ការសាងសង់ទំនប់វារីអគ្គិសនីសេសានក្រោម២ជាបន្ទាន់ និងវាយតម្លៃផលប៉ះពាល់បរិស្ថានឲ្យបានពេញលេញ ទៅតាមបទដ្ឋានអន្តរជាតិ។
- ធានាថា ក្រុមហ៊ុន Huaneng និងក្រុមហ៊ុន Hydrolancang មិនបន្តអនុវត្តគម្រោងនោះ ដោយពុំបានបង្ហាញព័ត៌មានលម្អិតនៃគម្រោងឲ្យបានល្អិតល្អន់ ដោយគ្មានការចូលរួមក្នុងការសម្រេចចិត្ត និងយល់ព្រមពីបណ្តាសហគមន៍ដែលប្រឈមផលប៉ះពាល់ ដោយយោងទៅតាមបទដ្ឋានជាតិ និងអន្តរជាតិ។
- ធានាថា ក្រុមហ៊ុនចិនដែលកំពុងវិនិយោគនៅបរទេស ប្រតិបត្តិតាមកាតព្វកិច្ចនៃច្បាប់អន្តរជាតិ និងគោលនយោបាយជាតិ របស់សាធារណរដ្ឋប្រជាមានិតចិន ដូចជា *គោលការណ៍ណែនាំសម្រាប់កិច្ចការពារបរិស្ថានក្នុងការវិនិយោគ និងក្រុមហ៊ុននៅបរទេស* និង *គោលការណ៍ណែនាំរបស់អង្គការសហប្រជាជាតិស្តីពីធុរកិច្ចនិងសិទ្ធិមនុស្ស*។ កាតព្វកិច្ចទាំងនេះរួមមាន ការបញ្ចូលការអនុវត្តប្រព័ន្ធគ្រប់គ្រងហានិភ័យបរិស្ថាននិង

[21] Principle 11, 13, 15.
[22] Principle 4.

សង្គម ទៅក្នុងដំណើរការធុរកិច្ច និងការចាត់វិធានការបង្ការឲ្យបានល្អ ដើម្បីធានាថា ផលប៉ះពាល់សិទ្ធិមនុស្ស ត្រូវបានកំណត់ និងកាត់បន្ថយ។

តាមការស្រាវជ្រាវបានបង្ហាញថា មានវិធីដែលជាជម្រើសផ្សេង ក្នុងការបង្កើតអំណាចដែលមាននិរន្តរភាព និងមានផលប៉ះពាល់បរិស្ថាននិងសង្គមតិច។ ជំរុញឲ្យបណ្តាក្រុមហ៊ុនចិនវិនិយោគតាមវិធីដែលជាជម្រើសផ្សេងទាំងនេះ អាចពង្រឹងភាពជាអ្នកឈានមុខ របស់ប្រទេសចិននៅក្នុងតំបន់ និងផលប្រយោជន៍កំណើនសេដ្ឋកិច្ច ដោយបំពេញសេចក្តីត្រូវការរបស់ប្រជាជនកម្ពុជាបាន។

សូមទទួលការគោរពដោយស្មោះពីយើងខ្ញុំ

3S Rivers Protection Network (3SPN)

Centre for Social Research and Development Vietnam (CSRD)

Community Economic Development Cambodia (CED)

Community Resources Centre of Thailand (CRC)

EarthRights International (ERI)

Fisheries Action Coalition Team of Cambodia (FACT)

International Rivers

Laofang Bundidterdsakul, Lawyer (Thailand)

Mekong Watch

My Village Cambodia (MVi)

NGO Forum on Cambodia (NGOF)

Northeastern Rural Development, Cambodia (NRD)

Samreth Law Group, Cambodia

Towards Ecological Recovery and Regional Alliance (TERRA)

Vietnam Rivers Network